**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
លេខៈ ០១៧ អ.ឧថហ/H-EQIP

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៧

**ជំរាបជូន**
**លោកប្រធានមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត**
**លោក-លោកស្រីប្រធានមន្ទីរសុខាភិបាលខេត្ត រាជធានី**

**កម្មវត្ថុ**: ការទូទាត់ចំណាយលើតាវកាលិក (កញ្ចប់ផលប្រយោជន៍) នៃកម្មវិធីមូលនិធិសមធម៌ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន លោក-លោកស្រីប្រធាន ជ្រាបថា ក្រសួងសុខាភិបាលបានបន្តទូទាត់ចំណាយលើតែថ្លៃសេវាវេជ្ជសាស្ត្រ ប៉ុណ្ណោះ នៅក្រោមកម្មវិធីមូលនិធិសមធម៌ ចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៦ នៅក្រោមគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល។ ដើម្បីឲ្យប្រជាពលរដ្ឋក្រីក្រមានលទ្ធភាពកាន់តែច្រើនឡើង ក្នុងការទទួលបានសេវាថែទាំសុខភាព ក្រសួងសុខាភិបាលនឹងបន្តចាប់ផ្តើមឡើងវិញការទូទាត់ចំណាយលើរបបអាហារសម្រាប់អ្នកកំដរអ្នកជំងឺ ថ្លៃធ្វើដំណើរ និងប្រាក់ឧបត្ថម្ភបុណ្យសពអ្នកជំងឺស្លាប់។ ការទូទាត់ចំណាយលើតាវកាលិកនៃមូលនិធិសមធម៌ត្រូវអនុវត្តតាមការណែនាំដូចខាងក្រោមនេះ៖

១. ការទូទាត់ចំណាយលើតាវកាលិកមូលនិធិសមធម៌ សម្រាប់ប្រជាពលរដ្ឋក្រីក្រដែលមាន «ប័ណ្ណសមធម៌» ហើយនៅមានសុពលភាព (តាមរយៈការវាយតម្លៃអត្តសញ្ញាណក្រីក្រទុកជាមុនដោយក្រសួងផែនការ) និងប្រជាពលរដ្ឋក្រីក្រដែលមាន «ប័ណ្ណអាទិភាព» ដែលបានវាយតម្លៃនៅមូលដ្ឋានសុខាភិបាល ហើយនៅមានសុពលភាព។

២. ការទូទាត់ចំណាយលើតាវកាលិកនៃមូលនិធិសមធម៌ នឹងចាប់ផ្តើមពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ នេះតទៅ នៅមន្ទីរមិត្តភាពខ្មែរសូវៀត មន្ទីរពេទ្យបង្អែករាជធានីខេត្ត មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព។

៣. ការទូទាត់ចំណាយលើតាវកាលិកនៃមូលនិធិសមធម៌ រួមមាន៖ ក) ថ្លៃសេវាវេជ្ជសាស្ត្រ ដែលបាននិងកំពុងអនុវត្តរហូតមកដល់បច្ចុប្បន្ន ខ) ថ្លៃសេវារបបអាហារសម្រាប់អ្នកកំដរម្នាក់ ចំពោះអ្នកជំងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យ គ) ថ្លៃធ្វើដំណើរមកមន្ទីរពេទ្យ និង ឃ) ឧបត្ថម្ភបុណ្យសពអ្នកជំងឺស្លាប់នៅមន្ទីរពេទ្យ។

៤.នីតិវិធីទូទាត់ចំណាយតាវកាលិកមូលនិធិសមធម៌ ត្រូវអនុវត្តតាម «គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការមូលនិធិសមធម៌» របស់ក្រសួងសុខាភិបាល ចុះថ្ងៃទី ២៨ វិច្ឆិកាឆ្នាំ២០១៦។

៥. មន្ទីរពេទ្យ និងមណ្ឌលសុខភាព (បើមណ្ឌលសុខភាពមានដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងការចុះបញ្ជិកាអ្នកជំងឺ PMRS ) ត្រូវគ្រប់គ្រង កត់ត្រានិងរក្សាទុកទិន្នន័យ នៃការប្រើប្រាស់សេវាសុខាភិបាល និងការទូទាត់ចំណាយ នៅក្រោមកម្មវិធីមូលនិធិសមធម៌ នៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងការចុះបញ្ជិកាអ្នកជំងឺ (PMRS) និងរក្សាទុកឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀត សម្រាប់ប្រើប្រាស់ក្នុងការរៀបចំសំណើសុំការទូទាត់ និងការត្រួតពិនិត្យនៅពេលក្រោយ ។ ខ.ៗ

៦. មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត មន្ទីរពេទ្យបង្អែករាជធានីខេត្ត និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ត្រូវរៀបចំសំណើរបុរេប្រទានថវិកាសម្រាប់រយៈពេលបីខែ កុម្ភៈ-មិនា-មេសា (ដោយសហការជាមួយគម្រោងគាំពារសុខភាពសង្គម នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ URC) មកឯកឧត្តមនាយកគម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល។ កន្លែងទទួលៈ នាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល អោយបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧។

អាស្រ័យដូចបានជំរាបជូនខាងលើនេះ សូមលោក លោកស្រីប្រធានពិនិត្យ និងចាត់ចែងអនុវត្ត តាមខ្លឹមសារខាងលើនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ។

សូមលោកលោកស្រីទទួលនូវការរាប់អានដ៏កក់ក្តៅអំពីខ្ញុំ។

**រដ្ឋលេខាធិការ និងជានាយក**
**គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល**

សាស្ត្រាចារ្យ **អេង_ហួត**

**ចម្លងជូនៈ**
-នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល
នាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ
-ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកទាំងអស់
-អ្នកអនុវត្តមូលនិធិសមធម៌ URC
-ឯកសារ-កាលប្បវត្តិ